ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៩៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការកែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និង វាយតំលៃ លើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រដោយសារ គំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ: ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ:នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤
- ប្រកាសលេខ ១៥១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤

### សំរេច

**ប្រការ ១ :** កែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតំលៃលើផលប៉ះពាល់សំណង់ផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជារាស្ត្រក្នុងគំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ ។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវបានកែសំរួលសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — ប្រធាន

២. ឯកឧត្តម **ខៀវ ចិស្សូត** អគ្គលេខាធិការរង នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — អនុប្រធាន

៣. ឯកឧត្តម **ស្វូត សំបូរ** អគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន — សមាជិក

៤. លោក ឆិត ចន្ថា អគ្គនាយករងទេសចរណ៍ នៃ ក្រសួងទេសចរណ៍ សមាជិក

៥. លោក ហ៊ុយ ណារ៉ា អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦. លោក សេខ ទារ៉ន្ធី ប្រធាននាយកដ្ឋានរដ្ឋបាល នៃ រដ្ឋលេខាធិការអាកាសចរស៊ីវិល សមាជិក

៧. លោក រស់ បរម អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨. លោកបណ្ឌិត ឈន សុភាព ប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសមាជិក

៩. លោក ជូ ទារ៉ន់នី អនុប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០.លោក មារក់ ម៉ុន្តរ៉ារិទ្ធ អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១.លោក ហ៊ីទ បញ្ញារតនា ប្រធានផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ នៃ អង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២.លោក ស៊ុន សុខនី ប្រធានផ្នែកគំរោង ADB និង WB នៃអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

ប្រការ ៣ : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីរបស់ប្រជារាស្ត្រ រួចធ្វើការវាយតម្លៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

ប្រការ ៤ : គណៈកម្មការនេះ មានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិស្នើសុំបង្កើតក្រុមការងារមួយដែលមានសមាសភាពមន្ត្រីជំនាញពាក់ព័ន្ធ សំរាប់បំពេញការងារប្រចាំថ្ងៃ ។

ប្រការ ៥ : ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ក្រសួងទេសចរណ៍, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ